**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៤០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់
# លេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ាំងនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំក្នុងវិស័យកីឡា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡានិងមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡា ចំណុះអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២៦០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ដែលហៅកាត់ថា លេខាធិការដ្ឋាន **គ.ប.ដ.ក.**។

## ជំពូកទី២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

លេខាធិការដ្ឋាន **គ.ប.ដ.ក.** មានតួនាទីជាសេនាធិការរបស់ **គ.ប.ដ.ក.** និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូន **គ.ប.ដ.ក.**
- រៀបចំនិងសម្របសម្រួលកម្មវិធីអប់រំ ផ្សព្វផ្សាយប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ផ្សព្វផ្សាយបទប្បញ្ញត្តិផ្សេងៗនិងអភិវឌ្ឍវិធានការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- រៀបចំចងក្រងឯកសារអប់រំប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- សម្របសម្រួលការប្រមូលសំណាកនិងត្រួតពិនិត្យសារធាតុដូប៉ាក្នុងចំណោមអត្តពលិក
- រៀបចំរបាយការណ៍វាយតម្លៃដំណើរការត្រួតពិនិត្យដូប៉ាឱ្យស្របតាមស្តង់ដាអន្តរជាតិជូន **គ.ប.ដ.ក.** ពិនិត្យនិងសម្រេច
- ចូលរួមនិងសម្របសម្រួលជាមួយអនុគណៈកម្មាធិការដោះស្រាយវិវាទដូប៉ានិងអនុគណៈកម្មាធិការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល
- ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិនិងក្រុមទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូន **គ.ប.ដ.ក.** ពិនិត្យនិងសម្រេច
- ជំរុញនិងតាមដានការអនុវត្តវិធានការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡារបស់សហព័ន្ធកីឡាជាតិនិងស្ថាប័នកីឡាពាក់ព័ន្ធ

- សម្របសម្រួលលើការលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- សម្របសម្រួលនិងចូលរួមកិច្ចប្រជុំកម្រិតជាតិ តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ធ្វើរបាយការណ៍អំពីលទ្ធផលវឌ្ឍនភាពប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាជូន **គ.ម.ដ.ក.** ពិនិត្យនិងសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ម.ដ.ក.**។

**មាត្រា៣ .-**

លេខាធិការដ្ឋាន **គ.ម.ដ.ក.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ប្រធានលេខាធិការដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ។

អនុប្រធានលេខាធិការដ្ឋានត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

អនុប្រធានលេខាធិការដ្ឋានបំពេញភារកិច្ចតាមការបែងចែកការងារពីប្រធានលេខាធិការដ្ឋាន។

**មាត្រា៤ .-**

លេខាធិការដ្ឋាន **គ.ម.ដ.ក.** មានសិទ្ធិប្រើរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន សម្រាប់ដំណើរការការងារ។

រូបសញ្ញារបស់លេខាធិការដ្ឋាន **គ.ម.ដ.ក.** ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

គំរូត្រារបស់លេខាធិការដ្ឋាន **គ.ម.ដ.ក.** ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

លេខាធិការដ្ឋាន **គ.ម.ដ.ក.** មានមន្ត្រីបម្រើការងារជាមន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនៃក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន **គ.ម.ដ.ក.** អាចមានអ្នកជំនាញការ និងអាចស្នើសុំមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះលេខាធិការដ្ឋាន **គ.ម.ដ.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៧ .-**

ត្រូវបានប្រែក្លាយនិងដំឡើងទីភ្នាក់ងារកម្ពុជាប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាដែលមានកំណត់នៅក្នុងប្រកាសលេខ៨៣៤ អយក.ប្រក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២ ស្ដីពីការបង្កើតទីភ្នាក់ងារកម្ពុជាប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ទៅជាលេខាធិការដ្ឋាន **គ.ម.ដ.ក.**។

ត្រូវបានផ្ទេរមន្ត្រីនិងថវិការបស់ទីភ្នាក់ងារកម្ពុជាប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡាមកបម្រើការងារជាមន្ត្រីនិងជាថវិការបស់លេខាធិការដ្ឋាន **គ.ម.ដ.ក.**។

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការចំណុះទីភ្នាក់ងារកម្ពុជាប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

ប្រកាសលេខ៨៣៤ អយក.ប្រក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតទីភ្នាក់ងារកម្ពុជាប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា

រូបសញ្ញារបស់លេខាធិការដ្ឋាន គ.ប.ដ.ក.

CADC
Play True
Cambodia Anti-Doping Committee

**អត្ថន័យនៃរូបសញ្ញា**
**លេខាធិការដ្ឋាន គ.ប.ដ.ក.**

១. រូបភាពកំពូលអង្គរវត្ត តំណាងឱ្យព្រះរាជាណាចក្រកម្ពុជា វប្បធម៌ អរិយធម៌ និងភាពរុងរឿងថ្កុំថ្កើងនៃព្រះរាជាណាចក្រកម្ពុជា។

២. ផ្ទៃពណ៌ស តំណាងឱ្យសាសនា ក្រមសីលធម៌ ចរិយាធម៌ សុចរិតភាព និងការគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៣. ពណ៌បៃតង តំណាងឱ្យធម្មជាតិ តុល្យភាព ភាពស្អាតស្អំ ស្រស់ស្រាយ និងការប្រកួតកីឡាដោយកម្លាំងពិត មិនក្លែងបន្លំ។

៤. ពណ៌ខ្មៅ តំណាងឱ្យភាពរឹងមាំ មុឺងម៉ាត់ និងការវិនិច្ឆ័យប្រកបដោយស្មើភាព មិនលំអៀង។

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា

គំរូត្រារបស់លេខាធិការដ្ឋាននៃ គ.ប.ដ.ក.